PTI0066

# សម្ភាសន៍ជាមួយឈ្មោះ ឈូក រ៉េម ភេទស្រី អាយុ៥១ឆ្នាំ

# មុខងារជំនាន់ខ្មែរក្រហម“កងចល័តស្រុក”

ស្រុកកំណើតនៅភូមិខ្ពស់ ឃុំរោងវែង ស្រុកកំពង់ត្រាច ខេត្តកំពត

រស់នៅភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់

ថ្ងៃទី២១ខែឧសភា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ សុខ វណ្ណៈ

០០:៥០:៤០

២៧ទំព័រ

វណ្ណៈ ចឹងថ្ងៃហ្នឹងថ្ងៃទី២១ខែ៥ឆ្នាំ២០១១ ខ្ញុំឈ្មោះសុខ វណ្ណៈណាមីងណា ។

រ៉េមៈ ចាស ។

វណ្ណៈ ខ្ញុំមកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ។

រ៉េមៈ ចាស ។

វណ្ណៈ ហើយខ្ញុំមកដល់ភូមិឃុំមីងដោយចង់ដឹងរឿងរ៉ាវបងប្អូនយើងដែលធ្លាប់ឆ្លងកាត់ប្រវត្តិមកដូរ ចត់យ៉ាងម៉េច ហើយជួបការលំបាកយ៉ាងម៉េចតាមផ្លូវអីហ្នឹងពីណាស់ ។

រ៉េមៈ ចាស ។

វណ្ណៈ ចឹងប្រវត្តិទាំងអស់ដែលខ្ញុំបានសម្ភាសជាមួយមីងហ្នឹង ខ្ញុំយកទៅចង់ក្រងឲ្យក្មេងបានដឹងបានព្ទុ ទុកសរសេរជាសៀវភៅ ។

រ៉េមៈ ចាស ។

វណ្ណៈ តើមីងយល់ព្រមទេ អនុញ្ញាតឲ្យខ្ញុំសរសេរជាសៀវភៅទេ?

រ៉េមៈ ចុះសរសេរៗទៅខ្ញុំមានឃាត់អី ។

វណ្ណៈ បាទ ។

រ៉េមៈ សើច... ។

វណ្ណៈ ជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះមីង មីងឈ្មោះអីដែរ?

រ៉េមៈ ឈ្មោះ រ៉េម ។

វណ្ណៈ ត្រកូល?

រ៉េមៈ ឈូក រ៉េម ។

វណ្ណៈ	មីងអាយុប៉ុន្មានហើយឥឡូវ?

រ៉ែមៈ	៥១ ។

វណ្ណៈ	៥១?

រ៉ែមៈ	ចាស ។

វណ្ណៈ	ប្ដីឈ្មោះអី?

រ៉ែមៈ	ប្ដីឈ្មោះ លាប ឈ្មោះ អ៊ឹម លាប ។

វណ្ណៈ	ចឹងគាត់នៅណារាល់ថ្ងៃ?

រ៉ែមៈ	គាត់ស្លាប់បាត់ហើយ ស្លាប់ជិត១០ឆ្នាំហើយ ។

វណ្ណៈ	ស្លាប់ដោយសារអី?

រ៉ែមៈ	ស្លាប់ដោយសាររោគក្រពះពោះវៀន គាត់ស្ទមីន ។

វណ្ណៈ	បាទ ។

រ៉ែមៈ	ស្ទម៉ាសេវ ។

វណ្ណៈ	បាទ ។

រ៉ែមៈ	តាមផ្លូវអីហ្នឹងគាត់ជាខ្មែរក្រហមដែរ ។

វណ្ណៈ	ចឹងមីងមានកូនប៉ុន្មាននាក់?

រ៉ែមៈ	ខ្ញុំកូនមានពីរនាក់ប្រុសមួយស្រីមួយ ។

វណ្ណៈ	ចឹងឪពុកមីងឈ្មោះអីដែរ?

រ៉ែមៈ	ឈ្មោះ ឈួន ឈូក ឈួន ។

វណ្ណៈ	ម្ដាយ?

រ៉ែមៈ	ម្ដាយ រាប ។

វណ្ណៈ	ស្អីគេរាបទៅ?

រ៉ែមៈ	រៀល រាប ។

វណ្ណៈ	រៀល?

រ៉ែមៈ	ចាស ។

វណ្ណៈ	ចឹងសព្វថ្ងៃគាត់នៅរស់ឬមួយស្លាប់ហើយ?

រ៉ែមៈ	គាត់ស្លាប់បីឆ្នាំអស់ហើយ ។

វណ្ណៈ	ចឹងស្លាប់ជិនាន់បីឆ្នាំ?

រ៉ែមៈ ចាស ។

វណ្ណៈ ស្លាប់ដោយសារអី?

រ៉ែមៈ ដោយសារគេយកវៃចោល ។

វណ្ណៈ ម៉េចបានជាមីងដឹង?

រ៉ែមៈ ខ្ញុំអីដឹងខ្ញុំអាយុ១៣ហើយ កាលជំនាន់ហ្នឹង ។

វណ្ណៈ បាទ ។

រ៉ែមៈ ឆ្នាំ៧៣ ។

វណ្ណៈ ចឹងវៃចោលតាំងពីឆ្នាំ៧៣នោះ?

រ៉ែមៈ ចាស!គាត់ជួញដូរស្រុកយួនគេមិនឲ្យទៅយើងលួចទៅគេចាប់បានគេយកទៅវៃចោល ។

វណ្ណៈ ចឹងស្រុកកំណើតមីង?

រ៉ែមៈ ខ្ញុំអ្នកកំពត ។

វណ្ណៈ ស្រុកកំណើតនៅភូមិអី?

រ៉ែមៈ ភូមិខ្ពស់ ឃុំរោងវែង ស្រុកកំពង់ត្រាច ខេត្តកំពត ។

វណ្ណៈ ចុះឥឡូវនៅភូមិអី?

រ៉ែមៈ ឥឡូវនៅភូមិប្រម៉ោយ ឃុំប្រម៉ាយ ស្រុកវាលវែង ខេត្តពោធិសាត់ ។

វណ្ណៈ ចឹងខេត្តពោធិសាត់មីង?

រ៉ែមៈ ចាស ។

វណ្ណៈ ចឹងសព្វថ្ងៃមីងប្រកបមុខរបរអីដែរ?

រ៉ែមៈ ខ្ញុំអ្នកចំការ ។

វណ្ណៈ ចឹងអ្នកចំការ?

រ៉ែមៈ ចាស!ដាំពោត សណ្តែក ។

វណ្ណៈ ចឹងកាលពីនៅតូចមានបានរៀនសូត្រអីដែរ?

រ៉ែមៈ ខ្ញុំបានរៀនតែភ្លេចអស់ហើយ ។

វណ្ណៈ រៀនបានថ្នាក់នាក់ទីប៉ុន្មាន?

រ៉ែមៈ ថ្នាក់ទី១ទី២ហ្នឹងឯង ។

វណ្ណៈ កាលពីដើមគេរាប់ពីធំមកមុនថ្នាក់ទី១២ទី១១អីចឹង ។

រ៉េមៈ យី!កាលហ្នឹងក្មេចហើយរៀន រៀនអត់ចេះផង ឥឡូវថាអត់បណ្តោយទៅ«អ្នកជិតនិយាយថាគាត់ទីទាល់» ។

វណ្ណៈ បាទ ។

រ៉េមៈ ទីទាល់អីខ្មែរក្រហម អស់ម៉ែអស់ឪយើងមិនអត់បានរៀន ។

វណ្ណៈ ចឹងដោយសារថាម៉ែឪស្លាប់តាំងពី៧៣?

រ៉េមៈ ចាស ។

វណ្ណៈ ចឹងមីងមានបងប្អូនប៉ុន្មាននាក់?

រ៉េមៈ បងប្អូនម្នាក់ឯង ។

វណ្ណៈ ចុះមានតែម្នាក់ហើយស្លាប់អស់តែម្តង?

រ៉េមៈ ចាស!នៅសល់ម្នាក់នៅជាមួយយាយ ។

វណ្ណៈ និយាយបងប្អូនបង្កើត?

រ៉េមៈ បង្កើតអត់មានផងមានតែម្នាក់ឯង ។

វណ្ណៈ ចឹងពេលកើតមីងមកហើយឪពុកម្តាយត្រូវគេយកទៅសម្លាប់ទៅ?

រ៉េមៈ ចាស!យកទៅសម្លាប់អស់ទៅ ។

វណ្ណៈ ចឹងមីងអភ័ពមានតែម្នាក់ឯង?

រ៉េមៈ ចាស ។

វណ្ណៈ ចឹងពេលកើតរដ្ឋប្រហារឆ្នាំ៧០មីងនៅប៉ុណ្ណា ឆ្នាំគេទម្លាក់គ្រាប់បែកអីយ៉ាងម៉េច មីងមានដឹងទេ កាលជំនាន់ទម្លាក់គ្រាប់បែកអី?

រ៉េមៈ កាលជំនាន់ហ្នឹងឆ្នាំ៧០ខ្ញុំមានអាយុ១០ឆ្នាំ ៧១អាយុ១១ ៧២អាយុ១២ ៧៣អាយុ១៣ចឹងទៅ ។

វណ្ណៈ ចឹងកាលហ្នឹងមីងមានដឹងថា មានការទម្លាក់គ្រាប់បែកមីងមានដឹងទេ?

រ៉េមៈ បេ៥២ហ្នឹង ។

វណ្ណៈ ហ្នឹងហើយបេ៥២ហ្នឹង?

រ៉េមៈ ដឹងតើ ។

វណ្ណៈ ដឹង?

រ៉េមៈ ទម្លាក់ក្រោយផ្ទះខ្ញុំជាប់ខ្នងភ្នំវិល្លិ ។

វណ្ណៈ បាទ ។

រ៉ែមៈ	គេយកម្ដាយខ្ញុំដាក់ក្នុងក្រឡុកហ្នឹងឯង ។

វណ្ណៈ	ចឹងមីងកាលហ្នឹងនៅតូចដែរ កាលខ្មែរក្រហមវ៉ៃភ្នំពេញបានថ្ងៃទី១៧មេសាឆ្នាំ១៩៧៥ ខ្មែរក្រហមឈ្នះទូទាំងប្រទេសមីងនៅក្នុងភូមិដដែលឬគេជ្រើសរើសមកកងចល័តឬក៏នៅហ្នឹង?

រ៉ែមៈ	ខ្ញុំនៅកងចល័តស្រុក ។

វណ្ណៈ	ឆ្នាំ៧៥ ?

រ៉ែមៈ	ឆ្នាំ៧៧កងចល័តស្រុក ។

វណ្ណៈ	ចឹងឆ្នាំ៧៥ ?

រ៉ែមៈ	៧៥ខ្ញុំនៅជាកុមារ ។

វណ្ណៈ	៧៥ នៅកុមារ៧៧?

រ៉ែមៈ	៧៧ចូលកងចល័តស្រុក ។

វណ្ណៈ	ស្រុកអីគេ?

រ៉ែមៈ	ស្រុកកំពង់ត្រាច ។

វណ្ណៈ	ចឹងកាលមីងនៅជាកុមារអីហូបចុកយ៉ាងម៉េចដែរ?

រ៉ែមៈ	កុមារដល់មានក្រុមបង្វាស់ដៃទៅបាយចែកគ្នា ។

វណ្ណៈ	បាទ ។

រ៉ែមៈ	ដួសមួយវែក១ចែកបបរចឹងទៅ ចែកបបរចែកដំឡូងចែកអីចឹងទៅ ។

វណ្ណៈ	បាទ ។

រ៉ែមៈ	មានដំឡូងចែកដំឡូងទៅមានបបរចែកបបរ ។

វណ្ណៈ	ចឹងដល់ពេលទៅនៅកងចល័តស្រុកបានហូបគ្រប់គ្រាន់ទេ?

រ៉ែមៈ	ដល់កងចល័តស្រុកស្ងោពោតក្រហមស្ងោតល្ងាចដល់ព្រឹកដល់ស្អែក ស្អែកដល់ព្រឹក ព្រឹកដល់ស្អែកស្ងោទាំងស្របកហូប ។

វណ្ណៈ	យ៉ាងម៉េចបានជាពិបាកចឹង ដូចថាបានទៅកងចល័តក្រែងខ្ញុំសួរថា?

រ៉ែមៈ	អត់ទេ ស្រុកខ្ញុំចឹងស្រូវបានចុះទៅយួនអស់ ។

វណ្ណៈ	យ៉ាងម៉េចបានទៅយួនវិញ?

រ៉ែមៈ	ខ្ញុំអត់ដឹងស្រូវធ្វើបានគេថាដឹកទៅយួនអស់មិនដឹងដែរ ។

វណ្ណៈ	មិនមែនដឹកទៅយួនទេ យើងមានត្រូវជាមួយយួនណា៧៧-៧៨អីហ្នឹងយើងវ៉ៃគ្នាហើយ?

រ៉ែមៈ	អត់ត្រូវទេ មាននេះកណ្ដាលនោះ ។

វណ្ណៈ មានកណ្ដាល?

រ៉ែមៈ វាត្រូវគ្នាចឹងដល់ហើយចឹងអស់ស្រូវដល់ហើយមុននិងរត់គេចាប់អាមេៗដាក់គុកអស់ ។

វណ្ណៈ ចឹងនៅកំពង់ត្រាចហ្នឹងពីណាជាគណៈតំបន់ប្រធានភូមិភាគអី?

រ៉ែមៈ គណៈតំបន់ពួកហ្នឹងភ្លេចហើយពួកហ្នឹងគេចាប់ទាំងអស់ ខ្ញុំភ្លេចបើស្រុកខ្ញុំស្គាល់ ។

វណ្ណៈ ស្រុកពីណាគេ?

រ៉ែមៈ ស្រុក តា សួស ។

វណ្ណៈ ចឹងតា សួស?

រ៉ែមៈ ចាស!តា សួសនិងក៏ក្បត់គេវៃចោលកាលរត់និងដែរ ។

វណ្ណៈ ចឹងចាប់ខ្លួនដែរ?

រ៉ែមៈ ចាស!ចាប់ខ្លួនដែរ ។

វណ្ណៈ ចឹងមានពីរណាទៀត ទៅជំនួសតា សួស?

រ៉ែមៈ ពេលដល់ចឹងខ្ញុំរត់ចូលព្រៃមក ចាប់កាលរត់និងតែម្ដង ។

វណ្ណៈ ចឹងនៅកំពតនិងគេហៅតំបន់ប៉ុន្មាន នៅកំពតកំពង់ត្រាចតំបន់លេខប៉ុន្មាន?

រ៉ែមៈ មិនដឹងតំបន់លេខប៉ុន្មានខ្ញុំមិនសូវចាំផង ភ្លេចអស់ហើយ ។

វណ្ណៈ ចឹងឆ្នាំ៧៧ហ្នឹងនៅកងចល័តស្រុកហើយមានចេញទៅខាងណាទៀតទេ?

រ៉ែមៈ អត់មានទៅណាទេ ខ្ញុំនៅហ្នឹងរហូតឃួនចូលត្រឹមមកតាមអន្តភាពមកចូលជាមួយគេរហូតចឹងខ្ញុំនៅកុមារល្មមដែលអាយុ១៧ តែក្មេងខ្ញុំក្រិនខ្ញុំតូចចឹងខ្ញុំចេះតាមគេមកដល់ហើយចឹងក៏តាមនារីគេតាមស្នាក់ការតាមអីចឹងមកនៅជាមួយគេរហូតរត់មកចូលព្រៃមក មានមេកងហ្នឹងគេយកមករហូតគេស្រឡាញ់ខ្ញុំក្មេងខ្ញុំអត់ចេះមាត់ចេះកអី ចឹងគេយកមករហូតមក ។

វណ្ណៈ បាទ ។

រ៉ែមៈ បានរួចមកបានខ្ញុំមកនៅភ្នំកំចាយភ្នំវល្លិភ្នំអីហ្នឹង ខ្ញុំមិនដែលចូលភូមិចូលអីផង ។

វណ្ណៈ បាទ!ចឹងកាលនៅកងចល័តស្រុកហ្នឹងមីងមានបានទៅស្រុកកំណើតអីដែរ?

រ៉ែមៈ ខ្ញុំបានទៅម្ដង ។

វណ្ណៈ ចឹង?

រ៉ែមៈ ហើយដល់ពេលរត់នោះរត់កាត់ភូមិម្ដង ។

វណ្ណៈ ចឹងកាលមីងនៅកងចល័តស្រុកមីងមានដឹងថាប្រជាជនអត់បាយនិងយកទៅសម្លាប់មីងមានដឹងទេ កាលហ្នឹង?

រ៉ែមៈ ដឹងគេយកពួក១៧យកទាំងអស់ ។

វណ្ណៈ យ៉ាងម៉េចមីងដឹង មីងដឹងតាមណា?

រ៉ែមៈ ខ្ញុំអីដឹងខ្ញុំនៅអង្គភាពហ្នឹងជ្រើសយកមកថាកន្លែងលុតដុំៗ គេយកមកឲ្យនៅកន្លែងស្រួលមានស្រួលណាគេយកមកវ៉ៃចោល យកមកវ៉ៃចោលនៅខ្នាចព្រៃហ្នឹង ។

វណ្ណៈ សម្លាប់នៅកន្លែងណា?

រ៉ែមៈ សម្លាប់ខ្នាចព្រៃហ្នឹង ជិតភ្នំវល្លិ៍ហ្នឹង ។

វណ្ណៈ ជិតភ្នំវល្លិ៍?

រ៉ែមៈ ចាស ។

វណ្ណៈ មានគុកដែលកាលហ្នឹង?

រ៉ែមៈ មាន ។

វណ្ណៈ គេហៅគុកអី?

រ៉ែមៈ ខ្ញុំមិនដឹងថាគុកអីដែរ ដឹងថាកន្លែងឃុំកន្លែងស្រុកមានគុកហ្នឹងឯង គុកនៅកន្លែងខ្ញុំនៅក្បែរផ្ទះ គុកហ្នឹង លួចមាន់មួយគេដេរអាមាន់គក វ៉ៃគោចឹងគេហៅអាវ៉ៃគោចឹងទៅ គេហៅអាតាគោចឹងទៅហើយគាត់អត់ឃ្លានមាំណាស់ គាត់ហៅគាត់ឃើញស្ពុពោតពួកខ្ញុំហូបអីគាត់រើសហូបចឹងទៅ ។

វណ្ណៈ ចឹងមីងមានឃើញអ្នក១៧មេសាគេដាក់គុកឬបណ្តើរយកទៅវ៉ៃចោលមីងមានឃើញទេ មានដែលឃើញផ្ទាល់ភ្នែកទេចឹងៗ?

រ៉ែមៈ ខ្ញុំអត់បានឃើញទេ ខ្ញុំឃើញតែគេនាំទៅធ្វើការហើយគេវ៉ៃក្តាំៗដើរយូរគេវ៉ៃក្តាំៗមានតែឆ្អឹងអីហ្នឹងឃើញ ឃើញស្គមគេវ៉ៃក្តាំៗឯងដើរឲ្យលឿនៗប្រញាប់ចឹងទៅ ទៅសែងអាអ្នកស្លាប់នៅគុកហ្នឹងសែងទៅស្គមពេកដួលគេវ៉ៃ ។

វណ្ណៈ ចឹងមីងភ័យទេ ពេលឃើញចឹង?

រ៉ែមៈ មនុស្សខ្ញុំវីងអត់មានចេះភ័យស្អីដែងអត់ចេះស្លុតដែង ដល់ឃើញរាល់ថ្ងៃពេលសាំមួយថ្ងៃសែងពីរមួយថ្ងៃសែងបី ដល់សែងចឹងទៅគ្នាដួលវ៉ៃក្តាំៗ លួចមាន់គកគេហៅអាមាន់គកចឹងទៅគាត់លួចមាន់គកគេហូបចឹងឈ្លបគេដឹងគេចាប់វ៉ៃទៅ តិចគេយកទៅដាក់កន្លែងហ្នឹងទៅកន្លែងគុកគេនិងទៅ ។

វណ្ណៈ ចឹងកន្លែងមីងហ្នឹងមានគ្នាប៉ុន្មាននាក់ កងចល័តស្រុក?

រ៉េមៈ	កាលឃើញហ្នឹងនៅកងចល័តឃុំនៅឡើយ ដល់ពេលចូលកងចល័តស្រុកអត់បានឃើញទេ បានដឹងថាគេយកមនុស្សទៅកន្លែងនោះកន្លែងនេះចឹងទៅហើយខ្ញុំដឹងថាគេវ៉ៃចោលដែរ ។

វណ្ណៈ	ចឹងកងចល័តស្រុកមានគ្នាប៉ុន្មាននាក់?

រ៉េមៈ	មានគ្នា៣០០ទៅ៤០០នាក់ មាន៤០០នាក់ ។

វណ្ណៈ	ចឹងកងចល័តហ្នឹងមានតួនាទីធ្វើអីទៅ ធ្វើស្រែ?

រ៉េមៈ	ធ្វើស្រែ ខែច្រូតៗដើរច្រូតតាមភូមិតាមឃុំចឹងទៅ ខែស្ទូងដកដើរតាមភូមិតាមឃុំទៅ ។

វណ្ណៈ	ចឹងមានចុះមកដល់ភូមិឃុំដែរ?

រ៉េមៈ	ចាស ។

វណ្ណៈ	មិនមែននៅខាងស្រុកទេ?

រ៉េមៈ	មិនមែនទេ ដើរចុះតាមភូមិតាមឃុំចឹងមកជួយចឹងទៅ ឃុំណាដែលគេតឹងតែងស្រូវគេស្រែធ្វើមិនទាន់ចឹង គេហៅឲ្យយើងទៅៗទៅជួយទៅ ។

វណ្ណៈ	ចឹងដូចថានៅកងចល័តស្រុកហ្នឹងគ្នា៤០០នាក់ចឹងពីណាជាអ្នកគ្រប់គ្រងជាប្រធាន?

រ៉េមៈ	ឈ្មោះ បង ជីព បង ថន ។

វណ្ណៈ	ហ្នឹងផ្នែកនារី?

រ៉េមៈ	ចាស ។

វណ្ណៈ	៤០០នាក់ហ្នឹងទាំងបុរសទាំងនារីឬយ៉ាងម៉េច?

រ៉េមៈ	តែនារី ។

វណ្ណៈ	ចឹងគាត់ត្រូវបានគេចាប់ខ្លួនដែលឬមួយអត់ទេ ឬមួយនៅរស់រហូតដល់ឆ្នាំ៧៩?

រ៉េមៈ	ខ្ញុំរស់រហូត ។

វណ្ណៈ	តែចង់និយាយមេៗហ្នឹង?

រ៉េមៈ	មេៗនៅទាំងអស់អត់បានគេចាប់ខ្លួនទេ អ៊ី!ចាប់មួយចាប់បងអីទេ ចាប់ដល់ហើយគាត់រត់រួចគាត់ទៅនៅយួនបាត់ទៅ ។

វណ្ណៈ	ចឹងកងនារី៤០០នាក់ហ្នឹងក្រោយមកមានបាត់ខ្លួនអីដែលមឹង?

រ៉េមៈ	បាត់ខ្លួនគេយកម្តងបួនដប់នាក់គេជ្រើសយកអ្នក១៧ហ្នឹង ជ្រើសយកម្តង២០ទៅ៣០នាក់ទៅម៉ាកងវរៈសេនាតូចឬម៉ាកងវរៈសេនាធំម្តងមាន៣០នាក់ចឹងទៅ គេយកទៅថានៅកន្លែងធ្វើការនេះកន្លែងធ្វើការនោះ ប៉ុនចឹងគេយកមកវ៉ៃចោលកន្លែងខ្វាចព្រៃ ។

វណ្ណៈ	ចឹងដល់ក្រោយមកនៅសល់ប៉ុន្មាននៅសល់តិចទេ?

វ៉ែមៈ មុនរត់ហ្នឹងនៅសល់ប្រហែលជា២៥០នាក់ ។

វណ្ណៈ ចឹងកន្លែងវ៉ៃចោលនៅខ្នាចព្រៃ?

វ៉ែមៈ ចាស ។

វណ្ណៈ ចឹងខ្នាចព្រៃហ្នឹងនៅជិតភ្នំវិល្ល?

វ៉ែមៈ ចាស ។

វណ្ណៈ ចឹងមីងម៉េចបានដឹងថាគេយកមកវ៉ៃចោលហ្នឹង?

វ៉ែមៈ ខ្ញុំអីមិនដឹងខ្ញុំមានបងប្អូនធ្វើគេហ្នឹងជាលួតជាទួតចឹងទៅគេធ្វើមេក្រុមគេធ្វើជាមេកងចឹងទៅដល់ហើយគេខ្សិបប្រាប់ខ្ញុំចឹងទៅខ្ញុំដឹងទៅ ។

វណ្ណៈ បាទ ។

វ៉ែមៈ ដល់ហើយគេយកម៉ែខ្ញុំទៅវ៉ៃចោលចឹងខ្ញុំធ្វើល្អ ទុកគេធ្វើយ៉ាងម៉េច ខទាហរណ៍គេឲ្យខ្ញុំទៅណាទៅរកត្រីទៅណា ទៅមើលគោទៅណា ចុះអូសត្រីឈើងទៀមប៉ុណ្ណាស៊ូអត់មានដែលមាត់អីមួយអឺស ។

វណ្ណៈ បាទ!ចឹងការងារជំនាន់មីងហ្នឹងធ្វើការងារអត់មានពេលសម្រាកអីខ្លះដែលអត់ទេ?

វ៉ែមៈ អត់ទេ សម្រាកតែយប់ យប់ម៉ោង៦អីមិនទាន់បានឈប់ស្នានេះវ៉ាន ។

វណ្ណៈ ចឹងកាលហ្នឹងមីងហូបពោតដល់ឆ្នាំណា?

វ៉ែមៈ ហូបពោតនិងឆ្នាំ៧៧ពេញធីងតែម្តង ។

វណ្ណៈ ចឹងហូបពោតមួយឆ្នាំ?

វ៉ែមៈ ចាស!ដល់ពេលរត់ប្រហែលជាបីខែបានហូបបបរ ស្លតែប្រលិត ។

វណ្ណៈ ហូបបបរគ្រប់គ្រាន់ទេ?

វ៉ែមៈ អត់ម្នាក់មួយវែក មួយវែងក្រឡូមហ្នឹងដល់ហើយចឹងខ្ញុំពត់ធ្វើឈឺចឹងបានហូបបបរហ្នឹងខ្ញុំហត់ទឹកអស់ហើយខ្ញុំសម្រិតទៅបានបាយប្រហែលមួយស្លាបព្រា ។

វណ្ណៈ ចឹងកន្លែងមីងមានហ្នឹងន័យថាអត់ឃ្លានដែរ?

វ៉ែមៈ អត់មែនទែនបណ្តោយ ។

វណ្ណៈ មនុស្សស្គមៗចឹងទៅ?

វ៉ែមៈ ស្បែកដណ្តប់ឆ្អឹងដានមនុស្សអាចម៍ជ្រូកចុះយើងហូបពោតទាំងស្រកី ។

វណ្ណៈ ចឹងមីងនៅកងចល័តស្រុកហ្នឹងពិបាកដូចប្រជាជនដែលចឹង?

រ៉ែមៈ ពិបាកអត់ដឹងផងប្រជាជន ប្រជាជនកន្លែងខ្លះអត់មានពិបាកប៉ុន្មានទេ មានបាយហូបគ្រាន់បើ តែសម្រាប់ពួកខ្ញុំតែម្ដងអត់មែនទែនបណ្ដោយ ។

វណ្ណៈ បាទ ។

រ៉ែមៈ លែងស្ងោតពោតព្រឹកដល់ល្ងាច ពោតក្រហមមុនដំបូងពោតស ពោតសគេចែកឲ្យប៉ិនកដៃម្នាក់មួយម្នាក់ពីរចឹងទៅមួយថ្ងៃ ។

វណ្ណៈ បាទ ។

រ៉ែមៈ ហើយពេលក្រោយមកចឹងទៅបានមានពោតក្រហមគេដាំពីខ្មាចព្រៃចឹងទៅគេថា ដាំពីខ្មាចព្រៃចឹងទៅយកទៅទាំងឡានៗចឹងទៅ អត់ដឹងគេដាំណាទេ តែគេថាខ្មាចព្រៃៗហ្នឹងយកពួក១៧ហ្នឹងពីណាខស្សាហ៍ដាំទៅ ណាខ្ជិលគេយកវ៉ៃចោលទៅ ។

វណ្ណៈ ចឹងពេលយកវ៉ៃចោលមីងមិនដែលឃើញទេ គ្រាន់តែដឹងថាគេយកៗ?

រ៉ែមៈ ចាស!មិនបានឃើញទេ ប៉ុន្តែបើរណ្ដៅខ្មោចតែម្ដងដើរជួបខ្ញុំទៅរកម្ដាយខ្ញុំ ។

វណ្ណៈ ឆ្នាំណា?

រ៉ែមៈ ឆ្នាំ៧៣ ។

វណ្ណៈ ៧៣ហ្នឹងខ្មែរក្រហមមិនទាន់វ៉ៃចូលភ្នំពេញទេ ៧៣ហ្នឹងនៅចលនាតស៊ូនៅឡើយ?

រ៉ែមៈ ហ្នឹងហើយ ។

វណ្ណៈ ចឹងកាលហ្នឹងមានរណ្ដៅខ្មោចតាំងពីឆ្នាំ៧៣មកម្លេះ?

រ៉ែមៈ ចាស!រណ្ដៅចុះបេ៥២ទម្លាក់ម្ដងម្កាលនោះ វាមិនចុចចំណុចៗដើងភ្នំដើងអី៧៣-៧៤ហ្នឹងខ្ញុំចូលដល់អាយុ១៦បានខ្ញុំបានចូលកងនារីឃុំ ចេញពី១៦ដបហ្នឹងចូលពាក់កណ្ដាលឆ្នាំហ្នឹងខ្ញុំមកនៅសាលាស្រុក ។

វណ្ណៈ កងចល័តស្រុក?

រ៉ែមៈ ចាស ។

វណ្ណៈ ចឹងកាលនៅចល័តឃុំបានឃើញគេសម្លាប់មនុស្ស?

រ៉ែមៈ បានឃើញគេសម្លាប់មនុស្សគេវ៉ៃមនុស្សវ៉ៃអីចឹងទៅ ដល់ពេលចូលចល័តស្រុកអត់ជួបទេ យើងតែស្រុកនេះ នៅអីក្បែរទល់ដែននេះ ។

វណ្ណៈ ទល់ដែនណា?

រ៉ែមៈ ទល់ដែនយួន ។

វណ្ណៈ ទល់ដែនយួនខាងកំពង់ត្រាចទល់ដែនយួន?

រ៉ែមៈ ចាស! នៅកំពង់ត្រាច នៅកាថៅបឹងសាលា ស្វាយទង ។

វណ្ណៈ ចឹងកាលហ្នឹងគណៈតំបន់គណៈភូមិភាគអីមីងអត់ស្គាល់ទេ?

រ៉ែមៈ ស្គាល់តែភ្លេចអស់ហើយ តែអ្នកនិងគេវៃចោលទាំងអស់ តា សួសគណៈស្រុកហ្នឹងក៏គេវៃចោលចុងក្រោយនេះ តា សួសហ្នឹង ។

វណ្ណៈ បាទ ។

រ៉ែមៈ ពេលរត់ហ្នឹងដល់គេថា តា សួសហ្នឹងទៅដល់ណាយួនទៅដល់ហ្នឹងដែរ ចឹងគេចាប់គាត់យកវៃចោលទៅ ។

វណ្ណៈ ចឹង?

រ៉ែមៈ ចាស ។

វណ្ណៈ ចឹងមីងធ្មើកងចល័តស្រុកនិងមីងធ្មើកងចល័តតែកំពង់ត្រាចមួយអត់មានទៅណាទៅណីទៀតទេ?

រ៉ែមៈ អត់មានទៅណាទេ នៅជួរតែព្រំដែនហ្នឹង នៅដុំភូមិស្វាយទង កាថៅបឹងសាលាចឹងទៅជួរៗមុខជាប់ៗព្រំដែនយួនហ្នឹង នៅតែមួយជួរហ្នឹង ។

វណ្ណៈ ហើយគេអត់មានដែលបញ្ជូនមីងមកភ្នំពេញអីទេ?

រ៉ែមៈ អត់ទេ ខ្ញុំកាលហ្នឹងជាសមាភាព ។

វណ្ណៈ យ៉ាងម៉េចបានជាប់?

រ៉ែមៈ ចុះបើគេយកម៉ែឪវៃចោលអស់ហើយ ។

វណ្ណៈ កាលម៉ែឪវៃចោលឆ្នាំ៧៣និងដោយសាររឿងអីទៅ?

រ៉ែមៈ ដោយសារគាត់ជួញដូរស្រុកយួនដែរ ។

វណ្ណៈ ចឹង?

រ៉ែមៈ ចាស! គេមិនឲ្យទៅហើយគាត់នៅតែទៅ ។

វណ្ណៈ ជួញអីគេនៅលក់ដូរ?

រ៉ែមៈ ជួញដូចថាខោអាវជួញអីចឹង ដូចថាយកដូងយកស្វាយទៅចឹងជារឺម៉កម៉ូតូចឹងទៅ ។

វណ្ណៈ បាទ ។

រ៉ែមៈ ហើយដល់គេមិនឲ្យទៅនៅលួចទៅរហូតឡើងម៉ោង១ម៉ោង២ចឹង ។

វណ្ណៈ ចឹងយកឥវ៉ាន់ទៅជួញស្រុកយួន?

រ៉ែមៈ យកពីយើងទៅយកទៅយួន យកពីយួនមកយកមកលក់ឲ្យយើង ។

វណ្ណៈ ចឹងទាំងម្តាយនិងឪពុក?

រ៉ែមៈ ចាស ។

វណ្ណៈ ទៅទាំងអស់គ្នាទាំងពីរនាក់ប្តីប្រពន្ធ?

រ៉ែមៈ ចាស ។

វណ្ណៈ ចឹងកាលហ្នឹងខ្មែរក្រហមប្រាប់ដែលតែយើងមិនធ្វើតាម?

រ៉ែមៈ អត់ យើងនៅចង់មានពេក ។

វណ្ណៈ ចឹងកាលហ្នឹងនៅចាយលុយ?

រ៉ែមៈ ចាស!នៅចាយលុយ ។

វណ្ណៈ ចឹងកាលយកទៅសម្លាប់និងមីងមានបានដឹងថា កន្លែងដែលគេសម្លាប់គាត់ទេ?

រ៉ែមៈ ដឹង!តែរកអត់ឃើញខ្មោចច្រើនពេក ។

វណ្ណៈ ចឹងមិនមែនសម្លាប់តែឪពុកម្តាយមីងទេមានអ្នកផ្សេងទៀត?

រ៉ែមៈ ចាស!គេចងទាំងខ្សែៗចឹងទៅ១៥០នាក់ចឹងទៅ ។

វណ្ណៈ ចឹង?

រ៉ែមៈ ចាស!ម៉ោង១២យប់ ម្តាយមីងខ្ញុំហ្នឹងតាខ្ញុំហើយតាឪពុកគាត់ហ្នឹងបងប្អូនបង្កើត ។

វណ្ណៈ បាទ ។

រ៉ែមៈ ដល់ពេលហើយចឹង ដល់ហើយចឹងម្តាយមីងនិងគាត់នៅជាប់និងផ្លូវគេបញ្ជូនមនុស្សទៅវ៉ៃចោលចឹង ដល់ពេលហើយចឹងថាគាត់ស្រែកហៅថា អូយខ្មើតអើយជួយបងផងអូនជួយបងផង ដល់ហើយចឹងអត់ហ៊ានទេ សម្ងំប៉ើមមិនហ៊ានឆ្លើយបង ។

វណ្ណៈ ចឹងមានមនុស្សរាប់រយនាក់ដែលដែលត្រូវស្លាប់ហ្នឹង?

រ៉ែមៈ ត្រូវស្លាប់និងគេយកទៅវ៉ៃចោលម្តង៥០ទៅ១០០ ។

វណ្ណៈ ចឹងមនុស្សមិនព្រមខ្លាចពេលដែលគេហាមឃាត់មិនឲ្យទៅជួញដូរស្រុកយួនចឹង?

រ៉ែមៈ ចុះមនុស្សមាន មានតែមួយប្រភេទហ្នឹងណា អត់មានអាហ្នឹងទេ មានដូចថា ហកយើងចូលមានសហករណ៍គេនិងមានក្រុមបង្ក្រាស់ដៃមានអីចឹងទៅ គេមកឲ្យយើងជំនាន់ហ្នឹងមានប្រហើរតិចៗហើយ ក្រុមអ្នកក្រីក្រហ្នឹងឆ្នាំ៧៣ហ្នឹងមានគេរើសឲ្យចូលក្រុមគេជួយខ្លះ ។

វណ្ណៈ ក្រុមអន្តការ?

រ៉ែមៈ ចាស!ក្រុមអន្តការគេជួយ គេជួយអ្នកអត់ខ្ញុំអត់ដែលតែខ្ញុំអ្នកកណ្តាលចឹងទៅណាស់ គេអត់ដាក់ថាអ្នកអត់ទេ គេដាក់ខ្ញុំកណ្តាល ។

វណ្ណៈ	បាទ ។

រ៉ែមៈ	ម្ដាយខ្ញុំយាយតាខ្ញុំហ្នឹង ដល់ហើយចឹងក៏ខ្ញុំមិនទាន់បានចូលអីនិងគេទេ ។

វណ្ណៈ	បាទ!ចឹងកាលប្រជាជនស្លាប់ជាមួយម្ដាយមីងនិងមានប្រជាជនប្រហែលជា១០០នាក់?

រ៉ែមៈ	ចាស!ប្រហែលជា១០០នាក់ មីងខ្ញុំប្រាប់ ។

វណ្ណៈ	ចឹងនៅពេលសម្លាប់ឪពុកម្ដាយមីងហើយ មីងមកនៅជាមួយពីណាវិញ?

រ៉ែមៈ	នៅជាមួយយាយ ។

វណ្ណៈ	ចឹងនៅជាមួយយាយរហូតទៅ?

រ៉ែមៈ	ចាស ។

វណ្ណៈ	ចឹងមីងកាលហ្នឹងនៅតូចមិនសូវដឹងអីទេកាលហ្នឹង?

រ៉ែមៈ	៧៣ខ្ញុំនៅតូចមនុស្សខ្ញុំក្រិន កើតមកតូចតែមួយ ។

វណ្ណៈ	ចឹងនៅជាមួយយាយរហូតដល់បានចូលកងចល័តអីចឹងទៅ?

រ៉ែមៈ	ចាស!ដល់បានចូលកងចល័តអីចឹងទៅ ។

វណ្ណៈ	ដល់បានទៅនៅស្រុកហើយវេទនាទៀត?

រ៉ែមៈ	វេទនារហូតមួយឆាកជីវិតនេះខ្ញុំវេទនាអត់មានបានស្រួលយ៉ាងណាទេ រហូតបានប្ដីបានតែមួយឆ្នាំគត់ប្ដីឈឺធ្លាក់ឈាមទៀត ខ្ញុំពិបាករហូតសព្វថ្ងៃនេះ ទើបឥឡូវបានធូរមិនសូវបានទៅស៊ីឈ្នួលគេណា ។

វណ្ណៈ	បាទ!ចឹងបានកូនប្រកបដោយធម៌ដែរ?

រ៉ែមៈ	ចាស!កូនខ្ញុំស្លូត ។

វណ្ណៈ	ចឹងមីងកាលវៀតណាមវ៉ៃចូលឆ្នាំ៧៩ហ្នឹង ហេតុអីបានជាមីងរត់?

រ៉ែមៈ	ខ្ញុំខ្លាចតែអុង ។

វណ្ណៈ	ខ្លាចតែអុងយ៉ាងម៉េចទៅ?

រ៉ែមៈ	ចុះគេថាយកមនុស្សដាក់ក្បាលធ្វើតែអុង ។

វណ្ណៈ	ចឹងចេះតែរត់តាមគេទៅ?

រ៉ែមៈ	រត់តាមធំៗតាមមេវរៈសេនាធំគេចឹងទៅ គេស្រឡាញ់ឃើញយើងប្រើអីក៏ធ្វើបានចឹងៗគេយកអត់មានដែលរករឿងអីចឹងទៅ នៅជាមួយគេរហូតទៅមាននារីមួយក្រុមកុមារតែខ្ញុំហ្នឹងឯងហើយខ្ញុំអាយុ១៧ហើយខ្ញុំកុហក់គេអាយុ១៣ឆ្នាំគេជឿ បើខ្ញុំនៅតូច៧៩ហ្នឹង ១៩ហើយខ្ញុំប្រាប់គេតែ១៣គេជឿដែរ ។

វណ្ណៈ តូចល្អិត?

រ៉ែមៈ ចាស ។

វណ្ណៈ មីងរត់ជាមួយពីណាខ្លះមានចាំឈ្មោះទេ?

រ៉ែមៈ ចាំឈ្មោះ រត់ជាមួយបង សុខប្រធានវរៈសេនាធំ ។

វណ្ណៈ វរៈសេនាធំ?

រ៉ែមៈ ចាស!វរៈសេនាធំនៅខេត្តភ្នំវ័ល្វ ។

វណ្ណៈ ឥឡូវគាត់នៅដែរ?

រ៉ែមៈ គាត់ស្លាប់បាត់ហើយយួនវ៉ៃស្លាប់បាត់ហើយ ។

វណ្ណៈ រហូតមកជាមួយគាត់រត់រហូតដល់ណាទៅ?

រ៉ែមៈ រត់ចឹងទៅឆ្លងថ្នល់ជាតិលេខ៤ ឆ្លងថ្នល់ជាតិលេខ៤ចឹងទៅ អះឆ្លងថ្នល់ជាតិលេខ៣ ឆ្លងថ្នល់ជាតិលេខបីចឹងទៅ ឡើងមកនៅខេត្តភ្នំកំចាយ នៅកំចាយចឹងទៅរហូតចេះនៅហ្នឹងចេះតែនៅៗរហូតជិតដាច់៧៩បានខ្ញុំចុះឡើងមកនេះ ឡើងមកនៅកោះកុងថ្មដានេះ ឡើងមកបានកន្លះខែឆ្នាំ៨០ ។

វណ្ណៈ បាទ!ចឹងកាលហ្នឹងរត់ប៉ុន្មានខែបានដល់កោះកុង?

រ៉ែមៈ យី! ជិតមួយឆ្នាំនោះ បើយើងគាំងពីដើមឆ្នាំ៧៨នោះ ។

វណ្ណៈ ម៉េចបានរត់គាំងពីឆ្នាំ៧៨បើយួនមិនទាន់ចូលផង?

រ៉ែមៈ យី!ចូលដើម៧៨អាអួន ៧៧គ្រាន់វ៉ៃជួរព្រំដែនទេ អាអួន ។

វណ្ណៈ ៧៩បានយួនចូល?

រ៉ែមៈ ៧៩យួនចូលឈិបពេញទាំងអស់ កន្លែងណាក៏វ៉ៃពីមុខវ៉ៃពីក្រោយដែលចុះយើងដើម៧៨ហ្នឹងមិនវ៉ៃជួរព្រំដែនហើយ ចូល៧៩ហ្នឹងយើងមិនរត់ ។

វណ្ណៈ ហ្នឹងហើយ ។

រ៉ែមៈ រត់រហូតអត់មានដែលស្គាល់ផ្ទះទេ ។

វណ្ណៈ ចឹងប្រហែលជា៧ទៅ៨ខែដែរ?

រ៉ែមៈ ចាស ។

វណ្ណៈ ចឹង៧៩ដល់កោះកុង?

រ៉ែមៈ ខ្ញុំនៅត្រឹមកំចាយបូកគោហ្នឹងយើងនេះហ្នឹងមានដល់កោះកុងណា ដល់ពេលជិតដាច់ឆ្នាំចូល៨០ហើយបានខ្ញុំមកដល់ហ្នឹង ។

វណ្ណៈ	ចឹងនៅភ្នំអីភ្នំកំចាយ?

រ៉ែមៈ	ភ្នំកំចាយ ។

វណ្ណៈ	ភ្នំកំចាយកំពតហ្នឹង?

រ៉ែមៈ	ចាស!ហើយខ្ញុំមកវៃឡានយកអង្ករនៅថ្នល់ជាតិលេខ៤នេះ ។

វណ្ណៈ	វៃជាមួយយួនទៀត?

រ៉ែមៈ	វៃយកអង្ករហូប ។

វណ្ណៈ	វៃជាមួយពីណា?

រ៉ែមៈ	វៃជាមួយយួនយកអង្ករហូបវៃឡានចឹងទៅឡានក្រឡាប់ចឹងទៅនាំគ្នាយកអង្ករហូបរត់ទៅភ្នំកំចាយវិញទៅ ។

វណ្ណៈ	ចឹងមានដែលបាញ់រទេះភ្លើងទេ?

រ៉ែមៈ	អត់ដែលទេ ដែលតែឡាន ឡានអាធំៗហ្នឹងដឹកទំនិញខ្ញុំធ្វើដូចកន្ទ្រៃបចឹង ។

វណ្ណៈ	ធ្វើយ៉ាងម៉េចទៅ?

រ៉ែមៈ	នាំគ្នាធ្វើដូចកន្ទ្រៃបចឹង ចុះដីខ្វងពិចនិលមិនចឹង មិនចំណោតចឹងនាំគ្នាតូបដូចកន្ទ្រៃបចឹងនាំគ្នាគោងមែកឈើចឹងទៅ ដល់ហើយចឹងគេត្រៀមៗខាងៗចឹងទៅ ។

វណ្ណៈ	បាទ ។

រ៉ែមៈ	ដល់ហើយគ្រាន់តែឃើញឡានចីវៗឃើញប៉ុនៗបាតដៃ ដល់ឃើញអាធំមកន្ទឹងៗទៅហួសមួយន្ទឹងៗៗដីងទីងៗៗក្រឡាប់ឡានបី ក្រឡាប់ឡានបីដល់អាខ្មែរក្រហមវាអត់ស្គាល់ផងកទៅឃើញអាកំប៉ុងថ្នាំលាបឡានលាបអីហ្នឹងនាំគ្នាថានំ ស៊ីយើងស៊ីឲ្យណាណីនាំគ្នាយកអាហ្នឹងស្ពាយដល់ពេលទៅគាស់ទៅ ថ្នាំលាបឡានលាបអីសោះ ។

វណ្ណៈ	ចឹង?

រ៉ែមៈ	ចុះកំប៉ុងថ្នាំមានស្គាល់ណា ។

វណ្ណៈ	បាញ់ឡានពីរបីបាញ់ឡានមកពីណាវិញឡានហ្នឹង?

រ៉ែមៈ	ឡានហ្នឹងមិនដឹងជាដឹកទំនិញមកពីណា ព្រោះថ្នល់ជាតិត្រង់ចឹងហើយ ។

វណ្ណៈ	ផ្លូវជាតិលេខ៤ទេ វាលវិញ?

រ៉ែមៈ	ចាស!ដល់ហើយដឹកចឹង ថ្នល់ជាតិទៅចឹងទទឹងថ្ងៃអីទេ ខ្ញុំវង្វេងអត់ដឹងផង ។

វណ្ណៈ	ផ្លូវទៅកំពង់សោមភ្នំពេញទេ?

រ៉ែមៈ	ចាស!ហ្នឹងផ្លូវហ្នឹង ។

វណ្ណៈ	បាញ់ឡាន?

រ៉ែមៈ	ចាស ។

វណ្ណៈ	បាញ់បេ?

រ៉ែមៈ	បាញ់បេ ទ្រឹងទឹង។ ។ បាល់ដើងឡានបីឡាននាំគ្នាទៅឃើញអង្គរលើចាក់ម៉ាកាំបិតជំពុះទង់ហ្នឹង លើទៅជ្រុះប៉ុន្មាននៅប៉ុន្មាននាំគ្នាយកទៅ ។

វណ្ណៈ	ចឹងអ្នកបើកឡានរត់រួចទេ?

រ៉ែមៈ	អើយតា កុងងាប់នៅក្នុងអង្គរហ្នឹងក្នុងព្រៃហ្នឹងបើបាញ់ឆេះខ្ទិចអស់ហើយ ។

វណ្ណៈ	ចឹង?

រ៉ែមៈ	ចាស ។

វណ្ណៈ	កាលតា កុងខ្មែរទេ?

រ៉ែមៈ	អត់ដឹងតាកុងខ្មែរដឹងតា កុងយួនបើមិនដឹងដែរ បើអត់ហូបហើយបើយើងមិនធ្វើចឹងម៉េចរស់ បាន ។

វណ្ណៈ	ចឹងម៉េចគ្រាន់តែស្មាក់។ ទៅ?

រ៉ែមៈ	យើស្មាក់យ៉ាងម៉េចបាន បើយួនត្រៀមមើលឃើញលឹម។ចឹងទៅ ពេលបាញ់ទៅដូចស្រមោច ចឹងលឹម។ចឹងមក ។

វណ្ណៈ	ចឹងបាញ់បានយកនេះទៅ?

រ៉ែមៈ	យកអង្ករហូប ។

វណ្ណៈ	ចឹងខ្ញុំសួរមីងបន្តទៀត?

រ៉ែមៈ	ចាស ។

វណ្ណៈ	ចឹងកាលហ្នឹងបាញ់ឡានបានអង្កររត់ចូលព្រៃទៀតទៅ?

រ៉ែមៈ	ចាស ។

វណ្ណៈ	ហើយដល់ឆ្នាំ៨០ បានមីងទៅកោះកុងវិញ?

រ៉ែមៈ	មកនៅនេះនៅថ្មដានេះ ។

វណ្ណៈ	ចឹងមីងថាកោះកុង?

រ៉ែមៈ	ហ្នឹងក៏កោះកុងថ្មដាកោះកុងហើយហ្នឹង គេហៅថ្មដាកោះកុង ។

វណ្ណៈ	បាទ ។

រ៉ែមៈ	កន្លែងឥឡូវនេះ ។

វណ្ណៈ ចឹងឆ្នាំ៨០ដល់ថ្មដាកោះកុង?

រ៉ែម: ចាស! ហ្នឹងគេហៅកោះកុងដែរ ។

វណ្ណៈ កាលមីងរត់មកមានគ្នាប៉ុន្មាននាក់?

រ៉ែម: ខ្ញុំរត់ច្រើនណាស់រាប់មិនអស់ទេ តែកន្លែងខ្ញុំនៅជាមួយតែម្តងមុនដំបូងមានគ្នា៣០នាក់ ។

វណ្ណៈ បាទ ។

រ៉ែម: អន្តរាគមន៍ហ្នឹងគេតាមអន្តរាគមន៍តាមកងគេចឹងអស់ពី៣០នាក់ចឹងទៅនៅសល់ពីរក្រុមសល់១០ទៅ ២០នាក់ចឹង អស់ពី២០នាក់នៅសល់តែ១៥នាក់ ។

វណ្ណៈ បាទ ។

រ៉ែម: ចុះខ្លះរត់ទៅផ្ទះទៅខ្លះគេនៅទៅ ។

វណ្ណៈ មានផាប់តាមផ្លូវមានឃើញទេ?

រ៉ែម: មានផាប់តើ ពួកខ្ញុំគាត់ឈឺស្លាប់ទៅគេឲ្យពួកខ្ញុំស្រី៥នាក់ គេឲ្យយាមហើយពេទ្យមួយគេឲ្យយាមហ្នឹងមើលអត់ជាក៏ស្លាប់ទៅនាំគ្នារត់មកទៀត ធ្វើដំណើរតាមផ្លូវមកទៀត ។

វណ្ណៈ ចឹងមីងមកដល់ថ្មបាំងថ្មដាហ្នឹងមីងធ្វើអីទៀតទៅ?

រ៉ែម: ខ្ញុំមកដល់នៅគេហៅកងដឹកជញ្ជូន ។

វណ្ណៈ ចឹងនារីនៅកងដឹកជញ្ជូន?

រ៉ែម: ចាស ។

វណ្ណៈ កាលហ្នឹងដឹកជញ្ជូនអីខ្លះទៅ?

រ៉ែម: ស្ពាយគ្រាប់ខោអាវ ។

វណ្ណៈ ខោអាវអន្តរចឹងទៅ?

រ៉ែម: អន្តរហូបខ្លួនឯង ខោអាវគាំភ្លើងគ្រាប់បែគ្រាប់អីមួយចប់ ។

វណ្ណៈ យកទៅឲ្យយុទ្ធជន?

រ៉ែម: យកទៅឆ្លងកាត់ត្រង់កន្លែងគេហៅនេះ ឆ្លងខាងនេះភ្នំនេះ ចេញពីភ្នំមកឆ្លងខាងនេះដើរមួយខែ បើមានសភាពការណ៍អត់ស្រួលដើរមួយខែបើសភាពការណ៍ស្រួលដើរ២៥ថ្ងៃ ខ្ញុំទៅដល់នេះជិតផ្លូវជាតិលេខ៨វិញ ។

វណ្ណៈ ដើរកាត់ព្រៃរហូត?

រ៉ែម: ចាស! ដើរកាត់ព្រៃរហូត ។

វណ្ណៈ អត់ខ្លាចទេ?

រ៉ែមៈ ខ្វាចអីបើដើរមានគ្នារាប់រយនាក់ម្តង ម្តង១០០អីនោះ ។

វណ្ណៈ អត់មានខ្វាចជាន់មីនទេ?

រ៉ែមៈ មានស្រីមានប្រុសមានតើផ្លូវ៥៦ហ្នឹង ពេលឆ្លងម្តងៗមានជាន់មីនអីចឹងទៅ ។

វណ្ណៈ ជាន់មីនសែងទៅវិញទៅ?

រ៉ែមៈ សែងទៅវិញទៅ អ្នកទៅមុខទៅទៀតទៅ អាអ្នកសែងៗបកទៅក្រោយវិញទៅ ។

វណ្ណៈ បាទ ។

រ៉ែមៈ ឥវ៉ាន់យកចែកគ្នាទៅគ្រាប់បេគ្រាប់«បេគ្រាប់អា កា គ្រាប់៤១គ្រាប់៦០អីក៏មានដែរ» ។

វណ្ណៈ ចឹងគ្រាប់និងសម្ភារទាំងអស់ហ្នឹងបានប្រទេសណាជំនួយឲ្យ?

រ៉ែមៈ ប្រទេសចិន ។

វណ្ណៈ ប្រទេសចិន?

រ៉ែមៈ ចាស ។

វណ្ណៈ យ៉ាងម៉េចបានជាមីងដឹងថាចិនជួយ?

រ៉ែមៈ ខ្ញុំដឹង ។

វណ្ណៈ ដឹងចឹងតែម្តង?

រ៉ែមៈ ចាស!ដឹងថាគ្រាប់មានពេញៗឃ្លាំងនៅថៃ ។

វណ្ណៈ ចឹង?

រ៉ែមៈ ចាស!ហើយដឹងថាខោអាវចិនជំនួយទាំងអស់ឲ្យពួកខ្ញុំទាំងអស់ ខ្ញុំអីមិនដឹង ។

វណ្ណៈ បាទ ។

រ៉ែមៈ បើខ្ញុំអាយុឡើង២០ហើយ ។

វណ្ណៈ បាទ ។

រ៉ែមៈ ខ្ញុំ' មកដល់មុនដំបូងតែបីក្រុមហ្នឹង ។

វណ្ណៈ ចឹងនៅខាងថ្មបាំងហ្នឹងពីណាជាប្រធានកងពលកាលសម័យក្រោយ៧៩ហ្នឹង?

រ៉ែមៈ តា បូរ៉ាន ។

វណ្ណៈ តា បូរ៉ាន?

រ៉ែមៈ ចាស!កូនប្រសាតា ម៉ុក ។

វណ្ណៈ ខ្ញុំមិនដែលឮឈ្មោះ?

រ៉ែមៈ មិនដែលឮអី គាត់ស្លាប់ព្រោះដឺរី ។

វណ្ណៈ បូរ៉ាន?

រ៉េមៈ ប្រធានធំហើយហ្នឹង ។

វណ្ណៈ កូនប្រសាគា ម៉ុក?

រ៉េមៈ ចាស ។

វណ្ណៈ ចឹងមីងស្គាល់គា ម៉ុកច្បាស់ទេ?

រ៉េមៈ ខ្ញុំមិនបានឃើញម្ដងមិនបានស្គាល់ច្បាស់ផង ។

វណ្ណៈ តែកូនគាត់?

រ៉េមៈ កូនគាត់ស្គាល់ច្បាស់តែម្ដង កូនគាត់កូនស្រីកូនប្រុសកូនប្រសា ។

វណ្ណៈ ចឹងបូរ៉ានហ្នឹងស្រីប្រុស?

រ៉េមៈ ប្រុស ។

វណ្ណៈ ប្រពន្ធគាត់ឈ្មោះអី?

រ៉េមៈ ឈ្មោះ ហ៊ាញ ។

វណ្ណៈ ឈ្មោះ ហ៊ាញ?

រ៉េមៈ ចាស ។

វណ្ណៈ កូនគា ម៉ុក?

រ៉េមៈ ចាស ។

វណ្ណៈ ចឹងបន្ទាប់ពីបូរ៉ានហ្នឹងមានពីណាទៀតកាលហ្នឹង?

រ៉េមៈ មានគា សឿង បងសឿងនៅវត្តធំមូល ។

វណ្ណៈ គាត់ឈ្មោះអីសឿង?

រ៉េមៈ អត់ដឹងផង ។

វណ្ណៈ ចឹងសព្វថ្ងៃនៅហ្នឹងដែរ?

រ៉េមៈ នៅ ។

វណ្ណៈ ឥឡូវគាត់ធ្វើអីហើយ?

រ៉េមៈ ឥឡូវគាត់គ្រូគាត់នៅខាងគ្រូ ។

វណ្ណៈ គាត់គ្រូខាងអី?

រ៉េមៈ គាត់គ្រូខាងអប់រំអីដឹង ។

វណ្ណៈ នៅខេត្ត?

រ៉ែមៈ	នៅខេត្តអីនៅយើងនេះ នៅជិតស្រុក ។

វណ្ណៈ	គាត់ជាអនុកងពល?

រ៉ែមៈ	ចាស ។

វណ្ណៈ	ប្រពន្ធគាត់ឈ្មោះអី?

រ៉ែមៈ	ឈ្មោះ បង វ៉ែន ។

វណ្ណៈ	ឈ្មោះ វ៉ែន?

រ៉ែមៈ	ចាស ។

វណ្ណៈ	នៅភូមិអី?

រ៉ែមៈ	នៅភូមិប្រម៉ោយ ឃុំប្រម៉ោយហ្នឹងដែរ ។

វណ្ណៈ	ចឹងតា សឿនហ្នឹងត្រកូលគាត់ស្គាល់ទេ?

រ៉ែមៈ	អត់ទេ ។

វណ្ណៈ	តា សឿនប្រពន្ធឈ្មោះវ៉ែន?

រ៉ែមៈ	ចាស ។

វណ្ណៈ	នៅភូមិប្រម៉ោយ ឃុំប្រម៉ោយហ្នឹង?

រ៉ែមៈ	ចាស ។

វណ្ណៈ	ចឹងគាត់រាល់ថ្ងៃជាគ្រូបង្រៀន?

រ៉ែមៈ	គាត់មិនដឹងខាងស្អីទេ គាត់នៅតែកន្ទែងអប់រំខាងអប់រំដឹង គាត់មិនដែលបង្រៀនផង ។

វណ្ណៈ	អប់រំស្រុក?

រ៉ែមៈ	ចាស!ខ្ញុំមិនដែលបានសួរអីផង ។

វណ្ណៈ	ឥឡូវគាត់ចាស់ហើយ?

រ៉ែមៈ	ចាស់ហើយ ។

វណ្ណៈ	ចឹងគាត់ចាស់ដែរ?

រ៉ែមៈ	ចាស ។

វណ្ណៈ	គាត់មិនសូវគាចទេ?

រ៉ែមៈ	ស្ងួត ។

វណ្ណៈ	គាត់មានទេសព្វថ្ងៃនេះ?

រ៉ែមៈ	គាត់មានគ្រាន់ដែលឥឡូវ ។

វណ្ណៈ	ចឹងប៉ូវ៉ានហ្នឹងគាត់ស្លាប់ដោយសារអី?

រ៉ែមៈ	ដោយសារគាត់បាញ់ជ័រ   គាត់ចេះហៅដូចហកឃើញដានជើងទន្សោង   គាត់ថាពួកនិងចង់ស៊ីទន្សោងអត់  បើថាហូបគាត់ហៅមកបាញ់ប៉ុន្មាន  ជ័រម្តង៧បាញ់នៅនេះ  នេះហួសវាលវែងបន្តិចហ្នឹង ។

វណ្ណៈ	គាត់ចេះហៅទៀត?

រ៉ែមៈ	ហៅ  ហៅជ័រឲ្យតែឃើញគាត់ចេះហៅដល់ចុងក្រោយគាត់ស្លាប់ព្រោះជ័រដែរ  ជ័រមិនដឹងជាហូបអស់ប៉ុន្មានទេ  រាប់រយខ្ញុំពួកខ្ញុំ ។

វណ្ណៈ	ចឹង?

រ៉ែមៈ	ទៅម្តងចឹងមួយជើងបាញ់ប្អូនទៅប្រាំចឹងទៅហូបសព្វសត្វអត់មានសល់អីទេ  ខ្លាំឃ្មុំសព្វទាំងអស់មុខសត្វ ។

វណ្ណៈ	ចឹងកាលនៅកងដឹកជញ្ជូនហ្នឹងហូបជ័រ?

រ៉ែមៈ	ចាស!និយាយម៉ាសត្វហូបទាំងអស់  ទន្សោង  ខ្ទីងវ័ល្លខ្ទីងមិនវ័ល្លអីហូបទាំងអស់  ប្រឹស ។

វណ្ណៈ	កាលហ្នឹងដូចថា ។

រ៉ែមៈ	នៅវាលវែងនេះ ។

វណ្ណៈ	កាលហ្នឹងសត្វច្រើនសម្បូរតែម្តង?

រ៉ែមៈ	អ៊ូស!គ្មានឆ្ងើលទេ  បាញ់ម្តងមាន២០ប្រឹសនោះ  សម្បូរណាស់ ។

វណ្ណៈ	អត់មានខ្លាចមនុស្សទេ?

រ៉ែមៈ	ចាស!អត់មានខ្លាចទេ  ជ័រខ្លាចប៉ុន្តែគាត់ចេះ  គាត់ចេះមេខ្យល់ចឹងទៅ  គាត់ដឹងមេខ្យល់ខទាហរណ៍ជ័រ២០ចឹង  គាត់ទៅបាញ់ពីមុខ  បាញ់មេខ្យល់ចឹងវាអត់មានទៅណារួចទេ  ម្តង៧ម្តង៣ ។

វណ្ណៈ	ចឹងសាច់ជ័រមឹងធ្លាប់ហូបដែរ?

រ៉ែមៈ	ហូបអស់ច្រើនណាស់ ។

វណ្ណៈ	ឆ្ងាញ់ដែរ?

រ៉ែមៈ	អត់មានឆ្ងាញ់ប៉ុន្មានផង  តែគ្រាន់បើជាងហូបត្រីខ ។

វណ្ណៈ	ចឹង?

រ៉ែមៈ	ពេលយើងជិតទៅចេះ  យើងមានអីមានតែត្រីខ  ត្រីខប្រហុក  ត្រីកាម៉ុង  សាច់មាន់កំប៉ុង  ប៊ីហើយសៀង  សៀងកំប៉ុង  ដល់យើងទៅចឹងយើងហូបសាច់ឆ្អើរ ។

វណ្ណៈ	ដល់ពេលចឹងជ័រដាន់គាត់ប្តូមួយយ៉ាងម៉េច?

រ៉ែម៖ គាត់បាញ់ដីរ៉ែភ្លុកខៀវ ស្តេចដីរ៉ែ ។

វណ្ណៈ ម៉េចបានដឹងថា ស្តេចដីរ៉ែ?

រ៉ែម៖ ដីរ៉ែបាញ់បានភ្លុករាប់មិនអស់ មានតែភ្លុកស អត់ដែលប៉ះអាភ្លុកខៀវហ្នឹងផង ដល់ចឹងគេថា ស្តេចដីរ៉ែ ដល់ហើយចឹងបាញ់ថ្ងៃហ្នឹងមានដីរ៉ែបី ដល់ហើយអាភ្លុកខៀវនិងមួយវាបុកដីមានតែផ្លុកម្នាងទេ វាបុកចូលដី ដល់ហើយចឹងគាត់និងក៏ផ្ទាសហើយក៏នាំគ្នាឆ្ពើរហើយព្រលឹមឡើងចេញទៅយួនកាត្រាក់មីនស្លាប់គាត់ទៅ ។

វណ្ណៈ ចឹងមិនមែនដោយសារដីរ៉ែជាន់ទេ?

រ៉ែម៖ អត់ទេ អត់ដោយសារដីរ៉ែជាន់ទេ?

វណ្ណៈ ដោយសារគ្រាប់វិញ?

រ៉ែម៖ ដោយសារមីនយួនកាត្រាក់ ។

វណ្ណៈ ចឹង?

រ៉ែម៖ ចាស ។

វណ្ណៈ ចឹងគាត់ពូកែចាប់សត្វតែម្តង?

រ៉ែម៖ គាត់ពូកែហៅតែម្តង គាតចេះបាលីហៅ ចង់បាញ់សត្វអីគាត់ឃើញដានគាត់ហៅមក បណ្តោយ ដីរ៉ែដានចាស់ៗហើយមិនដឹងទឹកល្អក់ពីកាលណា គាត់ថាពួកហ្នឹងស៊ីដីរ៉ែអត់ ថាហូបអើចាំបាញ់ គ្រាន់ដើរទៅមុខម៉ោង៨ហើយហ្នឹងប៉ុន្មានៗពេលព្រឹកមួយប្រលះចែកគ្នាទៅតាមក្រុមចឹងទៅ កងតូចតាមក្រុមទៅ ម្នាក់បួនទៅប្រាំគីឡូ១០គីឡូអីចឹងទៅ ។

វណ្ណៈ បាទ ។

រ៉ែម៖ មួយក្រុមគេហ្នឹង ។

វណ្ណៈ ចឹងកាលនៅកងដឹកជញ្ជូនហ្នឹងនៅខាងហ្នឹងមានតា បូរ៉ានមានតា សឿងអីហ្នឹង?

រ៉ែម៖ ចាស ។

វណ្ណៈ ចឹងមានដែលឃើញតា ម៉ុកឬកែវ ពក សុន សេន មកខាងហ្នឹងទេ?

រ៉ែម៖ ឃើញៗៗសម្ភាសនៅនេះនៅថ្នដានេះគាត់មកធ្វើស្ពានឆ្លងស្ទឹងមេទឹកហ្នឹង ឃើញតា ម៉ុក ឃើញខៀវ សំផន ឃើញ ប៉ុល ពត ឃើញ...។

វណ្ណៈ ឃើញសុន សេនហ្នឹង?

រ៉ែម៖ ចាស ។

វណ្ណៈ កាលគាត់មកគាត់មាននិយាយយ៉ាងម៉េចដែលទៅ?

រ៉ែមៈ ទេ ភ្លេចអស់ហើយគាត់មក គាត់សម្ភាសដូចថា ដូចថាយើងសម្ភាសដូចយើងសម្ពោធសាលាអីចឹងដែរ ហើយហ្នឹងគាត់មកសម្ពោធស្ពានណាស់ ដល់ហើយចឹងមានសិល្បៈមានអីលេងតាមអគ្គភាពចឹងមានគេវាំឲ្យមើលចឹងទៅ យកកុនចិនមកបញ្ចាំងឲ្យយើងមើលចឹងទៅ ។

វណ្ណៈ ចឹងមានដែលឃើញសម្ដេចសីហនុចុះមកទេ?

រ៉ែមៈ អត់ទេ ខ្ញុំ ។

វណ្ណៈ ចឹងពីកន្លែងនេះទៅព្រំដែនថៃមានប៉ុន្មានគីឡូទៀតដែលមីង?

រ៉ែមៈ ៩០គីឡូ ។

វណ្ណៈ ចឹងយើងអាចចេញចូលបានទេ?

រ៉ែមៈ បានផ្សារមានថ្ងៃគេបើកតើ ។

វណ្ណៈ ផ្លូវទៅស្រួលទេ?

រ៉ែមៈ តែទៅមុខឡើងភ្នំខ្វាំងបន្តិច ។

វណ្ណៈ ចឹងមានឡើងភ្នំដែរ?

រ៉ែមៈ ភ្នំឡើងភ្នំហ្នឹង ។

វណ្ណៈ មីងនៅហ្នឹងរហូតអត់មានរត់ទៅខាងសំឡូតទៅខាងម៉ាឡៃអីទេ?

រ៉ែមៈ អត់ទេ ខ្ញុំចេញពីហ្នឹងទៅឃួនវៃគៀ ទៅខ្ញុំចុះទៅក្រោម ចុះទៅក្រោមដល់ហើយខ្ញុំនៅសំឡូតដល់ហើយចឹងក៏គេជ្រើសកំលាំងពីសំឡូតមកធ្វើប៉ូលីស ប្ដីខ្ញុំធ្វើប៉ូលីសខ្ញុំមកនេះមក ។

វណ្ណៈ ធ្វើប៉ូលីសឆ្នាំណា?

រ៉ែមៈ ប៉ូលីសកាលយើងធ្វើសមាហរណ៍កម្មហើយហ្នឹង ។

វណ្ណៈ ឥឡូវយើងមិនទាន់និយាយដល់ហ្នឹងទេ យើងនិយាយកាលមីងនៅថ្មដាហ្នឹងក្រោយមកមីងរៀបការនៅឆ្នាំណា ដូចថាចាប់គូរអីមីងមានចាំទេ?

រ៉ែមៈ កាលជំនាន់ ។

វណ្ណៈ ជំនាន់ត្រូវគ្នាហើយឬមួយមុនហ្នឹង?

រ៉ែមៈ ត្រូវគ្នាហើយ ។

វណ្ណៈ ចឹងសមាហរណ៍កម្មហើយបានមីងការ?

រ៉ែមៈ ចាស!ត្រូវគ្នាកាលពេលអ៊ុនគាក់នោះ កាលជំនាន់អ៊ុនគាក់ ។

វណ្ណៈ ចឹង៩៣?

រ៉ែមៈ ចាស ។

វណ្ណៈ ៩៣អ៊ុនគាត់មិនទាន់ចូលដល់ហ្នឹងទេ?

រ៉េមៈ មិនទាន់ចូលប៉ុន្តែត្រូវរវូវគ្នាហើយប្ដីខ្ញុំទៅអារឈើឲ្យខាងក្នុងដីកហើយ ។

វណ្ណៈ ចឹង?

រ៉េមៈ ចាស ។

វណ្ណៈ ចឹងឈើចាប់ផ្ដើមកាប់បណ្ដើរៗហើយ?

រ៉េមៈ ចាស!កាប់យើងជួរៗមុខចឹង ។

វណ្ណៈ ហ្នឹងហើយ ។

រ៉េមៈ ប្ដីខ្ញុំគាត់ទៅគាត់ធ្វើមេកង ។

វណ្ណៈ ចឹងមីងការ៩៣មានភ្លេងការត្រឹមត្រូវហើយចឹង?

រ៉េមៈ អត់មានតែម៉ាញ៉ោចាក់ហើយមានផ្កាពីរបីទងដេរពាក់ហ្នឹងខ្ញុំបានការក្រោយគេ ។

វណ្ណៈ បានចាក់រាំទៅ?

រ៉េមៈ ចាស ។

វណ្ណៈ គេការមុនមីងទៀតគ្រាន់តែចាប់ដៃគ្នាប្ដេជ្ញាទេ?

រ៉េមៈ ចាប់ដៃគ្នាខ្ញុំមិនការ ខ្ញុំរើសប្ដីដែលរើសដែលប្ដី ខ្ញុំខ្លាចហត់ខ្លាចនឿយខ្ញុំហត់ពេកហើយអត់ដែលជួបការស្រណុកចឹង អញយកប្ដីមានកាំភ្លើងខ្ញីមាននិរសាមានអីបានអញយក ។

វណ្ណៈ ចឹងប្ដីមីងមាននិរសា?

រ៉េមៈ មាន ។

វណ្ណៈ ប្ដីមីងសក្ដិប៉ុន្មាន?

រ៉េមៈ វរៈសេនាតូចមិនដឹងជាសក្ដិប៉ុន្មានអត់ដឹងផង ។

វណ្ណៈ កាលហ្នឹងជំនាន់ខ្មែរក្រហម?

រ៉េមៈ ចាស ។

វណ្ណៈ ដល់ហើយក្រោយសមាហរណ៍កម្មហើយគាត់ចូលធ្វើជាប៉ូលីសម្ដង?

រ៉េមៈ ចាស ។

វណ្ណៈ ធ្វើប៉ូលីសហើយធ្វើយ៉ាងម៉េចទៀតទៅ?

រ៉េមៈ ធ្វើប៉ូលីសហើយដើរតែមើលចឹងទៅ ឥឡូវស្លាប់បាន១០ឆ្នាំហើយ ។

វណ្ណៈ ចឹងទើបស្លាប់ដែរ?

រ៉េមៈ ចាស ។

វណ្ណៈ ចឹងមីងដូចធ្លាប់ឆ្លងកាត់រឿងរ៉ាវជាច្រើនចឹង មីងគិតថាសម័យតស៊ូនិងសម័យឥឡូវហ្នឹង តើមានលក្ខណៈខុសគ្នាយ៉ាងម៉េច ថាឥឡូវស្រួលជាងក៏សម័យតស៊ូស្រួលជាង?

រ៉ែមៈ ឥឡូវស្រួលជាងកាលតស៊ូពិបាកណាស់ អត់បាយអត់ទឹកស្ដាយគ្រាប់ហ្នឹងទៅដាច់បាយអ្នកណាស្ដាយតិចស៊ីបបរអ្នកណាស្ដាយច្រើនស៊ីបាយ នាំគ្នាថាចឹង ។

វណ្ណៈ ហើយកាលហ្នឹងសង្គ្រាមមានយួនស្លាប់ច្រើនទេ?

រ៉ែមៈ យួន ។

វណ្ណៈ បាទ ។

រ៉ែមៈ កាលហ្នឹងជំនាន់រ៉ែមានស្លាប់ច្រើន ក្រោយមកខ្ញុំអត់បានឃើញទេ ។

វណ្ណៈ បាទ ។

រ៉ែមៈ យើងដឹងថាឆ្លងកាត់ផ្លូវនេះ ខាងៗចឹងនាំគ្នាស្រួលចឹងទៅ ។

វណ្ណៈ ចឹងមីនអីគេដោះអស់ហើយ?

រ៉ែមៈ នៅមួយៗ ។

វណ្ណៈ ចឹងបើយើងប្រហែលជាន់ទៀត?

រ៉ែមៈ ចាស! តែម្ដុំនេះអស់ហើយគ្មានទេ បន្ទាយគេនៅអូរកំបោរនេះ ។

វណ្ណៈ ចឹងមានតែកន្លែងបន្ទាយមានច្រើន?

រ៉ែមៈ ចាស ។

វណ្ណៈ ចឹងកាលហ្នឹងមីងមិនមានរត់ទៅជំរំទៅអីហ្នឹងគេរួច?

រ៉ែមៈ ទៅជំរំណាជំរំសាយខេហ្នឹងពួកខ្ញុំនៅតាមកងដដែល ។

វណ្ណៈ ចឹងអត់មានរត់ទៅអាមេរិចអី?

រ៉ែមៈ ទៅណាបើខ្ញុំមកគេលែងរើសយកហើយ ។

វណ្ណៈ ចឹង?

រ៉ែមៈ ចាស ។

វណ្ណៈ ចឹងគេលែងយកហើយ?

រ៉ែមៈ ចាស! កាល៧៩តែម្ដងគេយកដល់ឆ្នាំ៨០ហើយគេលែងយកហើយ ។

វណ្ណៈ ចឹងគេលែងយកហើយ?

រ៉ែមៈ ចាស! គេមានតែបញ្ជូនខ្មែរឡើងវិញ ។

វណ្ណៈ ចឹងមីងមានដឹងថាថៃកាលហ្នឹងត្រូវជាមួយយើងម្លេះហើយឥឡូវក៏មិនត្រូវចឹង?

រ៉ែមៈ អត់ដឹងដែរ អត់ដឹង ដឹងថាត្រូវជាមួយវាវ៉ៃនៅថ្ងៃនោះជួយវ៉ៃទៀត ជួយវ៉ៃយើងទៀត វ៉ៃគ្មានចេះក្រាបអីផង លូនចង់ងាប់ ។

វណ្ណៈ ថៃ?

រ៉ែមៈ ចាស!ស្រួលណាស់ចែកថ្ងៃនេះបើសិនថា វាវ៉ៃគ្រប់ច្រកល្ហកថ្ងៃនេះវិញ បាញ់ទៅមើលឃើញផ្ទះស១ដាក់១២២ ដេកា ៣៧អីចុចទៅងាប់ខ្ទិចឥឡូវ ។

វណ្ណៈ ចឹង?

រ៉ែមៈ ចាស ។

វណ្ណៈ ចឹងបើវ៉ៃជាមួយថៃមឹងចង់ទៅវ៉ៃទៀត?

រ៉ែមៈ យី!រលាយបឹងកកខ្សុលឲ្យទៅវ៉ៃ ។

វណ្ណៈ វាមានកាំភ្លើងច្រើនជាងយើង?

រ៉ែមៈ កាំភ្លើងច្រើនក៏វានេះដែរ ព្រោះយើងនៅពីលើវានេះថ្ងៃនេះយើងនៅពីលើវា យើងមើលច្រកកន្លែងដែលថាយើងមើលឃើញចឹងផ្ទះស១ឃើញភ្លើងភ្លឺយប់ឡើងអី ។

វណ្ណៈ ចឹងមើលឃើញច្បាស់ចេះតែម្តង?

រ៉ែមៈ ចាស!ចុះយើងនៅពីលើវា ។

វណ្ណៈ ចឹងចុចក្តាំងងាប់ខ្ទិច?

រ៉ែមៈ ចាស!ដាក់តែ១២២ អា១០០លី៣៧ដាក់ទៅចុចតាមថ្ងពិលទៅប៉ឹង១គ្រឹង១១ចុចតែមិនស្រួលបែរមកក្រោយវិញ ។

វណ្ណៈ ចឹងកាលវ៉ៃគ្នាហ្នឹងមឹងមានភ័យទេ?

រ៉ែមៈ មឹងមិនចេះភ័យទេ ។

វណ្ណៈ អត់ចេះភ័យទេ?

រ៉ែមៈ ចាស!មិនងាយចេះស្លុតទេ ។

វណ្ណៈ ចឹងពេលវ៉ៃចេះតែទៅទោះបីវ៉ៃរបួសស្លាប់យ៉ាងម៉េចក៏មិនស្លុត?

រ៉ែមៈ អត់ចេះស្លុត ។

វណ្ណៈ ចឹងមឹងសំណាងដែលអត់មានដាច់ដៃដាច់ជើង?

រ៉ែមៈ អត់ ។

វណ្ណៈ ឆ្ងងកាត់ផុតទាំងអស់នេះ?

រ៉ែមៈ ផុតទាំងអស់ ចុះមានឆ្លងផ្លូវចឹងទៅរួចអត់មីអូន បង បូរ៉ានគាត់ថាទៅរួចអត់ពីអូន ពីអូនឯង ដេកបន្តិចសិនទៅ លក់ក្អឹប ទៅរួចអត់ពីអូនមកសួរទៀតហើយណាស់ ។

វណ្ណៈ បាទ ។

រ៉ែមៈ ម៉ោង៣ចាំប្រហែលជា២០០ទៅ៣០០ម៉ែត្រពីផ្លូវ រួចអត់ពីអូន អត់រួចទេ ដឹកទឹកទាំងអស់ មិនស្រួលកងឈ្លបជាន់មីន មេកងឈ្លបជាន់មីនហើយ ឯងម៉េចថាចឹង ថាម៉េចចាំមើលទៅ គ្រាន់ហើយយប់ជាងហ្នឹងបន្តិចជាន់មីនបឹងៗនាំគ្នារត់ឈុលទៅក្រោយវិញអស់រលីង ។

វណ្ណៈ កាលហ្នឹងមីនច្រើនណាស់?

រ៉ែមៈ ចាស ។

វណ្ណៈ ចឹង«ក៥»មានចុះមកដល់ខាងហ្នឹងទេ?

រ៉ែមៈ «ក៥»ហ្នឹងក៥កាប់នៅហ្នឹងហើយពួកខ្ញុំដើរកន្លែង«ក៥» ហ្នឹងពេលអត់ដឹងវាត្រៀមដែលខ្ញុំ ប្រាប់គាត់ពេលបកមកវិញ គាត់សួរមីអូនយើងឆ្លងរួចអត់ យប់ហ្នឹងឆ្លងរួចអត់ជាចម្ងាយ កំណាត់បងឯងទៅមុខខ្ញុំទៅក្រោយវិញ មានអីមិនដឹងវាត្រៀមពីកាលចុះកងឈ្លបៗដើរចុះ ឡើងយើងអត់មានបាញ់រលីង ពេលថ្ងៃម៉ោង៦អត់បាញ់មិនដឹងជាយ៉ាងម៉េច ។

វណ្ណៈ «ក៥»កាលហ្នឹងគេយកមកធ្វើអីដែលកាលហ្នឹង?

រ៉ែមៈ ក៥គេយកមកកាប់ព្រៃចេញពីផ្លូវ១០០ម៉ែត្រៗ កុំឲ្យពួកដឹកជញ្ជូនខ្ញុំស្ពាយគ្រាប់ដើរកាត់ ។

វណ្ណៈ ចឹងឲ្យស្រួលមើល?

រ៉ែមៈ ចាស!ដល់ពេលហើយវាលាស់បំពង់ឡើង មានមើលឃើញណាវានៅក្នុងបំពង់ព្រៃថ្មីក ។

វណ្ណៈ ចឹងព្រៃហ្នឹងកាប់ចោលអត់មានយកទៅណា?

រ៉ែមៈ គេកាប់រំលំៗឲ្យវាដេកគងៗលើគ្នាចឹងទៅ ។

វណ្ណៈ មានដុតចោលទេ?

រ៉ែមៈ អត់ដុតទេ គេដាក់កុំឲ្យពួកខ្ញុំឆ្លង ។

វណ្ណៈ ចឹងឈើហ្នឹងក្រោយមកយកទៅលក់បានទៀត?

រ៉ែមៈ អត់មានលក់ទេ ។

វណ្ណៈ ចឹងអាដើមធំៗ ?

រ៉ែមៈ កាលហ្នឹងដើមធំៗគេអត់កាប់ទេ គេកាប់តែដើមប៉ុនៗនេះ ។

វណ្ណៈ ចឹងនៅស្រុកភូមិនេះគេចូលចិត្តដាំដំណាំអីជាងគេ គេដាំប្រចាំថ្ងៃរាល់ថ្ងៃ?

រ៉ែមៈ ប្រចាំថ្ងៃរាល់ថ្ងៃហ្នឹង ។

វណ្ណៈ	បាទ ។

វ៉ែមៈ	មានល្ងតាមវដ្ដវចាប់ពីខែ២ទៅសណ្ដែក  ពោតក្រហម ។

វណ្ណៈ	ចឹងគេបង្កើតភូមិឃុំមានផ្លូវអីចឹងនៅឆ្នាំណា?

វ៉ែមៈ	អត់ចាំទេ     ប៉ុន្មានឆ្នាំហើយប្រហែលជា១០ឆ្នាំហើយព្រោះប្ដីខ្ញុំធ្វើផ្លូវធ្វើអីហើយគាត់ឈឺធ្លាក់ខ្លួនមើលទៅ ។

វណ្ណៈ	បាទ ។

វ៉ែមៈ	មកវិញស្លាប់ ។

វណ្ណៈ	បាទ!ចឹងមីងមានអីចង់និយាយទៀតទេ     ដែលមីងមិនទាន់និយាយ     មីងមានចង់បន្ថែមចង់និយាយរឿងអីទៀតទេ?

វ៉ែមៈ	អត់មានអីផង ។

វណ្ណៈ	ចឹងខ្ញុំអរគុណមីងច្រើនហើយ ។

វ៉ែមៈ	ចាស ។

វណ្ណៈ	ចឹងអរគុណច្រើនដែលមីងបានផ្ដល់បទសម្ភាសរឿងរ៉ាវដែលទាក់ទងនិងសម័យឆ្លងកាត់កន្លងមកណាមីងណាស់ ។

វ៉ែមៈ	ចាស ។

**ចប់**